(៣)ខែ បន្ទាប់ពីទទួលបានដី ហើយសមាជិកគ្រួសារម្នាក់ត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍នៅលើដីនោះយ៉ាងតិចប្រាំមួយ (៦) ខែក្នុងឆ្នាំនីមួយៗ។



- អ្នកទទួលដីមិនអាចលក់ ជួល បរិច្ចាគ ឬឲ្យគេចាំជំនួស សម្បទានដីសង្គមកិច្ចនេះបានឡើយនៅក្នុងរយៈពេលប្រាំ(៥)ឆ្នាំដំបូង នៃការអនុវត្តតាមកិច្ចសន្យាសម្បទានដីសង្គមកិច្ច។

**ការទទួលខុសត្រូវ និងសិទ្ធិសំខាន់ៗទាំង៦ចំណុចរបស់អ្នកទទួលសម្បទានដីសង្គមកិច្ច ពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)(អនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ១៨)**



- ប្រសិនបើគ្មានសំណង់លំនៅឋាននៅលើសម្បទានដីសង្គមកិច្ចនោះទេ អ្នកទទួលដីត្រូវសាងសង់យ៉ាងហោចណាស់ផ្នែកណាមួយនៃលំនៅឋានអចិន្ត្រៃយ៍ក្នុងអំឡុងពេលបី

# LASED

**គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ

**គាំទ្រដោយ**

THE WORLD BANK

giz GOPA CONSULT

សម្រាប់ព័ត៌មានបន្ថែមពីសម្បទានដីសង្គមកិច្ច និងគម្រោង LASED សូមទំនាក់ទំនង:
- មេភូមិ ឬ មេឃុំ
- ការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីរាជធានី/ខេត្ត
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ(អគសសជ)

បោះពុម្ពដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច នៃក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និង សំណង់
ចំនួន ៥០០០សន្លឹក នៅខែកញ្ញា ឆ្នាំ ២០១២
អាសយដ្ឋាន: អគារលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ,
Email: lased@ezecom.com.kh



• អ្នកទទួលសម្បទានដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវដាំដំណាំឲ្យបានជាប់លាប់នៅលើដីនោះក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីបានទទួលដី ហើយត្រូវបន្តប្រើប្រាស់ដីនោះស្របតាមលក្ខខណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ច។

• ប្រសិនបើអ្នកទទួលសម្បទានដីសង្គមកិច្ចណាម្នាក់ស្លាប់នៅពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចទាយាទនៅក្នុងគ្រួសាររបស់គាត់អាចបន្ត



អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរហូតដល់ប្រាំ (៥) ឆ្នាំ ទើបមានសិទ្ធិកម្មសិទ្ធិលើដីនោះ។

• ប្រសិនបើអ្នកទទួលសម្បទានដីសង្គមកិច្ចខកខានមិនបានបំពេញតាម



លក្ខខណ្ឌកាន់កាប់និងប្រើប្រាស់សម្បទានដីសង្គមកិច្ចទេ ដីនោះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញដើម្បីធ្វើការបែងចែកសាជាថ្មី។



• បន្ទាប់ពីអនុវត្តបានយ៉ាងត្រឹមត្រូវតាមលក្ខខណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ចរយៈពេលប្រាំ (៥) ឆ្នាំ អ្នកទទួលដីមានសិទ្ធិកម្មសិទ្ធលើដីនោះ ហើយអាចដាក់ពាក្យស្នើសុំ ប័ណ្ណកម្មសិទ្ធិដី ស្របតាមនីតិវិធីដែលបានកំណត់នៅក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។